**OAKLAND UNIFIED SCHOOL DISTRICT**

*Community Schools, Thriving Students*

# តើមាននរណាម្នាក់ក្នុងក្រុមគ្រួសាររបស់លោកអ្នក មានការធានារ៉ាប់រងសុខភាពហើយឬនៅ? សង្កាត់សាលារៀនអូកឡិនដ៍អាចជួយលោកអ្នកបាន!

សង្កាត់សាលាអូកឡិនដ៍ យកចិត្តទុកដាក់ចំពោះសុខភាពនៃក្រុមគ្រួសាររបស់លោកអ្នក។ លោកអ្នកអាចទទួលបាននូវការជួយចុះឈ្មោះឱ្យនរណាម្នាក់ក្នុងក្រុមគ្រួសាររបស់លោកអ្នក សំរាប់ការធានារ៉ាប់រងសុខភាព តាមរយៈមជ្ឈមណ្ឌលធនធានគ្រួសារនៃសង្កាត់សាលារៀនអូកឡិនដ៍ OUSD ដែលមានទីតាំងនៅក្នុងបរិវេណ Lakeview Campus នៅអាស័យដ្ឋាន 746 Grand Ave។ សូមទូរស័ព្ទមកធ្វើការណាត់ជួប តាមរយៈទូរស័ព្ទលេខ (510) 273-1516។ ទីនេះមានអ្នកលើកទូរស័ព្ទជាប្រចាំនៅចន្លោះម៉ោង 8:30 ព្រឹកដល់ម៉ោង 12 ថ្ងៃ ហើយនិងពីម៉ោង 1 ថ្ងៃដល់ម៉ោង 4:30 រសៀល ហើយសារទូរស័ព្ទ នឹងត្រូវបានឆ្លើយតបវិញនៅថ្ងៃបន្ទាប់។ មជ្ឈមណ្ឌលនេះ អាចជួយក្រុមគ្រួសារផងដែរ ក្នុងការចុះឈ្មោះសំរាប់កម្មវិធី CalFresh (ដែលពីដើមគេហៅថា៖ food stamps) ឬទទួលបាននូវម្ហូបអាហារបន្ទាន់ពីឃ្លាំងផ្ទុកស្បៀងអាហារ Alameda County Community Foodbank។

ខាងក្រោមនេះ គឺជាព័ត៌មានអំពីកម្មវិធីសុខភាពខុសៗគ្នា ដែលលោកអ្នកអាចមានសិទ្ធិទទួល។ សូមមើលម្ខាងទៀតនៃទំព័រនេះ សំរាប់តារាងកំណត់ប្រាក់ចំណូល ដែលក្នុងនោះមានព័ត៌មានថែមទៀតអំពីភាពមានសិទ្ធិទទួលការធានារ៉ាប់សុខភាព។ សូមទូរស័ព្ទមកចុះ បើសិនជាលោកអ្នកមានសំណួរ ឬត្រូវការជួយ!

## កម្មវិធីមេឌីខល (MEDI-CAL)

មេឌីខល (Medical) គឺជាកម្មវិធីធានារ៉ាប់រងសុខភាពនៃរដ្ឋកាលីហ្វូនញ៉ា ដែលផ្ដល់ការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃ ដល់មនុស្សពេញវ័យ និងដល់កុមារដែលមានប្រាក់ចំណូលទាប។ មនុស្សពេញវ័យត្រូវតែមានវត្តមានស្របច្បាប់នៅក្នុងសហរដ្ឋ (មានសញ្ជាតិជាអាមេរិកាំង, មានទីលំនៅស្របច្បាប់អចិន្ត្រៃយ៍, មានទិដ្ឋាកា U ឬ T Visa,  មានសិទ្ធិជ្រកអាស្រ័យ) ដើម្បីឱ្យមានសិទ្ធិទទួលបាននូវកម្មវិធីនេះ។ តាមច្បាប់ថ្មីរបស់រដ្ឋកាលីហ្វូនញ៉ា កុមារដែលគ្មានវត្តមានស្របច្បាប់ក្នុងសហរដ្ឋ ឥឡូវនេះ អាចមានសិទ្ធិទទួលបាននូវមេឌីខលពេញលេញ។

*ជាឧទាហរណ៍៖* បើសិនជាគ្រួសារលោកអ្នកសមាជិក 4 នាក់ ហើយមានប្រាក់ចំណូល 2,887 ដុល្លារ ឬតិចជាងនេះ ក្នុងមួយខែៗ ហើយមានវត្តមានស្របច្បាប់នៅក្នុងសហរដ្ឋនោះ សមាជិកទាំងអស់ក្នុងគ្រួសារ អាចមានសិទ្ធិទទួលបាននូវមេឌីខល។ កុមារអាចនៅតែមានសិទ្ធិទទួលនូវកម្មវិធីនេះ បើទោះបីជាមាតាបិតារបស់ពួកគេ ពុំមានវត្តមានស្របច្បាប់នៅក្នុងសហរដ្ឋក៏ដោយ។ ប្រាក់ចំណូលមានកំរិតសំរាប់កុមារនោះ គឺខ្ពស់ជាមនុស្សពេញវ័យ។

## ទីផ្សារ COVERED CALIFORNIA

កម្មវិធី Covered CA គឺជាទីផ្សារធានារ៉ាបរងសុខភាព ដែលបានបង្កើតឡើងដោយច្បាប់ Affordable Care Act (ហៅកាត់ OabamaCare)។ បើសិនជាលោកអ្នកមានប្រាក់ចំណូលខ្ពស់ ដែលពុំអាចមានសិទ្ធិទទួលកម្មវិធីធានារ៉ាប់រងសុខភាពនោះ លោកអ្នកអាចជាវការធានារ៉ាប់រងសុខភាពបាន តាមរយៈទីផ្សារ Covered California។ លោកអ្នកត្រូវតែមានវត្តមានស្របច្បាប់នៅក្នុងក្នុងសហរដ្ឋ ដើម្បីឱ្យមានសិទ្ធិទទួលកម្មវិធីធានារ៉ាប់រងសុខភាពតាមរយៈទីផ្សារ Covered California។ ប្រាក់ជំនួយសំរាប់បង់ប្រចាំខែ ឬការបន្ថយការចេញថ្លៃរួមគ្នា គឺមានសំរាប់ក្រុមគ្រួសារដែលស្ថិតនៅក្នុងស្ថានភាពប្រាក់ចំណូលណាមួយ។

*ជាឧទាហរណ៍៖* បើសិនជាក្រុមគ្រួសារលោកអ្នក មានសមាជិក 4 នាក់ ដែលមានប្រាក់ចំណូលនៅចន្លោះ 2,888  ដុល្លារ និង 8,200 ដុល្លារ ក្នុងមួយខែៗ ហើយមានវត្តមានស្របច្បាប់នៅក្នុងសហរដ្ឋនោះ សមាជិកទាំងអស់ក្នុងគ្រួសារ អាចមានសិទ្ធិទទួលបាននូវការធានារ៉ាប់រងសុខភាពតាមរយៈទីផ្សារ Covered CA អមដោយប្រាក់ជំនួយពីរដ្ឋសំរាប់បង់ខែ (រដ្ឋាភិបាលជួយចេញថ្លៃបង់ប្រចាំខែឱ្យលោកអ្នក)។ ជួនកាលមាតាបិតាមានសិទ្ធិទទួលបាននូវការធានារ៉ាប់រងសុខភាពតាមរយៈទីផ្សារ Covered CA ខណៈដែលកុមារមានសិទ្ធិទទួលបាននូវមេឌីខល ដោយសារតែប្រាក់ចំណូលមានកំរិត សំរាប់កុមារ និងមនុស្សពេញវ័យ។

## កម្មវិធីសុខភាពនៃខោណធីអាឡាមីដា (HealthPAC)

កម្មវិធីសុខភាពអាឡាមីដា (HealthPAC) គឺជាកម្មវិធីប្រចាំខោណធីអាឡាមីដា ដែលផ្ដល់សិទ្ធិទទួលបាននូវការថែសុខភាពដោយឥតគិតថ្លៃ ឬតាមការបញ្ចុះថ្លៃ ដល់មនុស្សពេញវ័យ ឬដល់កុមារ ដែលមានប្រាក់ចំណូលទាប ហើយដែលពុំមានសិទ្ធិទទួលមេឌីខលពេញទំហំ។ ពលរដ្ឋដែលមានសញ្ជាតិជាអាមេរិកាំង ពុំត្រូវការកម្មវិធីនេះទេ។ កម្មវិធី HealthPAC គឺពុំមានមែនជាកម្មវិធីធានារ៉ាប់រងសុខភាពទេ ប៉ុន្តែវាជាមធ្យោបាយមួយក្នុងការទទួលការបំរើសេវាវេជ្ជសាស្ត្រ នៅតាមគ្លីនិកណាមួយនៅក្នុងខោណធីអាឡាមីដា។

*ជាឧទាហរណ៍៖* បើសិនជាគ្រួសារលោកអ្នកសមាជិក 4 នាក់ ហើយមានប្រាក់ចំណូល 4,184 ដុល្លារ ឬតិចជាងនេះ ក្នុងមួយខែៗ ហើយមានវត្តមានស្របច្បាប់នៅក្នុងសហរដ្ឋនោះ សមាជិកទាំងអស់ក្នុងគ្រួសារ អាចមានសិទ្ធិទទួលបាននូវកម្មវិធី HealthPac នេះ។

*សំគាល់៖ ទំហំប្រាក់ចំណូលទាំងអស់ ត្រូវចុះសំរាប់ប្រាក់ចំណូលមុនត្រូវបានបូតពន្ធ។ ទំហំក្រុមគ្រួសារ រួមមានទាំង មាតាបិតា ឬអ្នកអាណាព្យាបាល និងកូនៗទាំងអស់។*

មេឌីខល គឺធានារ៉ាប់រងកុមារ មិនគិតអំពីឋានៈអន្តោប្រវេសន៍ឡើយ ហើយនិងធានារ៉ាប់រងមនុស្សពេញវ័យដែលមានទីលំនៅស្របច្បាប់នៅក្នុងសហរដ្ឋ។ សូមមើលតារាងកំណត់ប្រាក់ចំណូលសំរាប់កម្មវិធីនានានៅខាងក្រោមនេះ៖

| តារាងកំណត់ប្រាក់ចំណូលសំរាប់មេឌីខល | | | |
|---|---|---|---|
| ទំហំគ្រួសារ | មនុស្សពេញវ័យអាយុ 18 é 64* | មានវ័យចាស់ និងពិការ | កុមារអាយុ 0 é 18 |
| | ប្រាក់ចំណូលខ្ពស់បំផុតប្រចាំខែ | ប្រាក់ចំណូលខ្ពស់បំផុតប្រចាំខែ | ប្រាក់ចំណូលខ្ពស់បំផុតប្រចាំខែ |
| 1 | $1,397 | $1,012 | $2,692 |
| 2 | $1,893 | $1,372 | $3,649 |
| 3 | $2,390 | $1,732 | $4,607 |
| 4 | $2,887 | $2,092 | $5,564 |
| 5 | $3,384 | $2,452 | $6,522 |

*សំរាប់ស្ត្រីមានផ្ទៃពោះ ដែលមានប្រាក់ចំណូលច្រើនលើសចំនួនកំណត់ប្រាក់ចំណូលប្រចាំខែនោះ អ្នកអាចនៅតែមានសិទ្ធិទទួលបាននូវការបំរើសេវា “សំរាប់តែការមានផ្ទៃពោះ” នៅក្នុងត្រីមាសទី 1 និងទី 2 របស់អ្នក។

កម្មវិធី Covered CA ធានារ៉ាប់រងក្រុមគួសារ ដែលមានទីលំនៅស្របច្បាប់នៅក្នុងសហរដ្ឋ។ សូមមើលតារាងកំណត់ប្រាក់ចំណូលសំរាប់កម្មវិធីនៅខាងក្រោមនេះ៖

| តារាងកំណត់ប្រាក់ចំណូលសំរាប់ COVERED CALIFORNIA | | | | |
|---|---|---|---|---|
| ទំហំគ្រួសារ | ប្រាក់ចំណូលប្រចាំឆ្នាំ | ប្រាក់ចំណូលប្រចាំខែ | ប្រាក់ចំណូលប្រចាំឆ្នាំ | ប្រាក់ចំណូលប្រចាំខែ |
| 1 | $16,754 - $30,150 | $1,398 - $2,513 | $30,150 - $48,240 | $2,514 - $4,020 |
| 2 | $22,715 - $40,600 | $1,894 - $3,384 | $40,600 - $64,960 | $3,385 - $5,414 |
| 3 | $28,677 - $51,050 | $2,391 - $4,255 | $51,050 - $81,680 | $4,256 - $6,807 |
| 4 | $34,638 - $61,500 | $2,888 - $5,125 | $61,500 - $98,400 | $5,126 - $8,200 |
| 5 | $40,600 - $71,950 | $3,385 - $5,996 | $71,950 - $115,120 | $5,997 - $9,594 |
| ចំនួនទឹកប្រាក់ដែលត្រូវបង់ប្រចាំខែ | ផ្តល់ប្រាក់ជំនួយ និងការបន្ថយការឱ្យចេញថ្លៃបង់រួមគ្នា | | ផ្តល់ឱ្យតែប្រាក់ជំនួយទេ | |

កម្មវិធី HealthPac គឺសំរាប់ក្រុមគ្រួសារដែលពុំមានវត្តមានស្របច្បាប់នៅក្នុងសហរដ្ឋ។ សូមមើលតារាងកំណត់ប្រាក់ចំណូលសំរាប់កម្មវិធីទាំងពីរ នៅខាងក្រោមនេះ៖

| តារាងកំណត់ប្រាក់ចំណូលសំរាប់កម្មវិធីសុខភាពនៃអាឡាមីដា (HealthPAC) | | | |
|---|---|---|---|
| ទំហំគ្រួសារ | ប្រាក់ចំណូលប្រចាំខែ | ប្រាក់ចំណូលប្រចាំខែ | ប្រាក់ចំណូលប្រចាំខែ |
| 1 | $0 - $1,397 | $1,398 - $1,518 | $1,519 - $2,024 |
| 2 | $0 - $1,893 | $1,894 - $2,058 | $2,059 - $2,744 |
| 3 | $0 - $2,390 | $2,391 - $2,598 | $2,599 - $3,464 |
| 4 | $0 - $2,887 | $2,888 - $3,138 | $3,139 - $4,184 |
| 5 | $0 - $3,384 | $3,385 - $3,678 | $3,679 - $4,904 |
| ប្រាក់បង់ថែមពីលើ | | | |
| សង្គ្រោះបន្ទាន់ | $0 | $35 | $50 |
| អ្នកជម្ងឺក្នុងមន្ទីរពេទ្យ | $0 | $100 | $100 |
| អ្នកជម្ងឺក្រៅមន្ទីរពេទ្យ | $0 | $10 | $15 |
| ហ្វាម៉ាស៊ី | $0 | $5 | $5 |
| ករណីពិសេស | $0 | $100 | $100 |

Last Revised 05/31/2018